១៥-អនុសេនីយ៍ទោ	**ឃឹម វាសនា**	០២១៧៥០	មេបញ្ជាការរង កងល្បាតទី៤	កងការពារព្រំដែនលេខ៥០៣
១៦-អនុសេនីយ៍ទោ	**កេង លឹម**	០៣០៨២៤	មេបញ្ជាការរង កងល្បាតទី៥	កងការពារព្រំដែនលេខ៥០៣
១៧-អនុសេនីយ៍ទោ	**ឡុង ឆាយហៀ**	០៣៤៩៣៦	មេបញ្ជាការរង កងល្បាតទី៥	កងការពារព្រំដែនលេខ៥០៣
១៨-អនុសេនីយ៍ទោ	**កែវ ណារិន**	០១៩៩៧៧	មេបញ្ជាការរង កងល្បាតទី៥	កងការពារព្រំដែនលេខ៥០៣
១៩-អនុសេនីយ៍ទោ	**ញឹប គុំ**	០៣៦៦៦៦	មេបញ្ជាការរង កងល្បាតទី៦	កងការពារព្រំដែនលេខ៥០៣

២០-អនុសេនីយ៍ទោ ទូ មន្ថូលី ០២១២៨៧ មេបញ្ជាការរង កងល្បាតទី៦ កងការពារព្រំដែនលេខ៥០[illegible]

២១-អនុសេនីយ៍ទោ គិត្យ វ៉េង ០១៩៣៩១ ជំនួយការអប់រំចិត្តសាស្ត្រ កងការពារព្រំដែនលេខ៥០[illegible]

២២-អនុសេនីយ៍ត្រី នាយ ផា ០៣៣៤១៨ នាយផ្នែកសុខាភិបាល កងការពារព្រំដែនលេខ[illegible]

២៣-អនុសេនីយ៍ត្រី ឈួន អ៊ីម ០៣៧៤៣៦ មេបញ្ជាការរង កងល្បាតទី២ កងការពារព្រំដែនលេខ៥០[illegible]

២៤-អនុសេនីយ៍ត្រី ម៉ុន ចាន់រតនា ០៩៣៧៩៩ មេបញ្ជាការរង កងល្បាតទី៦ កងការពារព្រំដែនលេខ៥០[illegible]

២៥-អនុសេនីយ៍ត្រី ឈី សុខាវណ្ណនា ០៣៥០១០ មេបញ្ជាការរង កងល្បាតទី៣កងការពារព្រំដែនលេខ៥០[illegible]

២៦-អនុសេនីយ៍ត្រី អ៊ុច មុនីរ៉ា ០៣០៨១៧ មេបញ្ជាការរង កងល្បាតទី៦ កងការពារព្រំដែនលេខ៥០៣

២៧-ព្រិន្ទបាលឯក ម៉ុំ ឆន ០៥៥០៤១ ជំនួយការអប់រំចិត្តសាស្ត្រ កងការពារព្រំដែនលេខ[illegible]

២៨-ពលបាលឯក ខាន់ សោរ៉ៃ ០៣៧២៦១ នាយចរន្តឡាក្នុង កងការពារព្រំដែនលេខ[illegible]

២៩-នាយឯក ទៀង ស៊ីរ៉ាត ០១១៨៦០ បុគ្គលិកផ្នែកហិរញ្ញវត្ថុ កងការពារព្រំដែនលេខ[illegible]

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៤៣ អនក្រ.តត

អនុក្រឹត្យ
ស្ដីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ១៤៩ គ្រឿង ជូនកងឯកភាព នាយទាហាន នាយទាហានរង និងពលទាហាន កងពលតូចលេខ២១ យោធភូមិភាគទី២ អគ្គបញ្ជាការដ្ឋាន ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម ÷

ក-មេដាយមាសការងារជូនកងឯកភាព :

១ -កងពលតូចលេខ ២១	យោធភូមិភាគទី២
២ -វរសេនាតូចលេខ ២១១	កងពលតូចលេខ ២១
៣ -វរសេនាតូចលេខ ២១២	កងពលតូចលេខ ២១
៤ -វរសេនាតូចលេខ ២១៣	កងពលតូចលេខ ២១
៥ -វរសេនាតូចលេខ ២១៤	កងពលតូចលេខ ២១

-មេដាយមាសការងារ ជូនបុគ្គល :

១-	ឧត្តមសេនីយ៍ត្រី	អ៊ុន ស៊ីដារ៉ា	០០០ ១៤៧	មេបញ្ជាការកងពល	កងពលតូចលេខ ២១
២-	វរសេនីយ៍ឯក	សៅ កុសល	០០០ ៤០៦	មេបញ្ជាការរង	កងពលតូចលេខ ២១
៣-	វរសេនីយ៍ឯក	ជាំ ហៃ	០០០ ៤០២	មេបញ្ជាការរង	កងពលតូចលេខ ២១
៤-	វរសេនីយ៍ឯក	សុខ គុន	០០០ ៤០៤	មេបញ្ជាការរង	កងពលតូចលេខ ២១
៥-	វរសេនីយ៍ឯក	ជឹម ធឿន	០០០ ៤០៥	មេបញ្ជាការរង	កងពលតូចលេខ ២១
៦-	វរសេនីយ៍ឯក	ជេត ម៉ុន	០០១ ០៤៥	មេបញ្ជាការរង និងនាយសេនាធិការ	កងពលតូចលេខ ២១
៧-	វរសេនីយ៍ទោ	ចាន់ ប៊ុនថន	០០១ ០៤៣	នាយរងសេនាធិការ	កងពលតូចលេខ ២១
៨-	វរសេនីយ៍ទោ	ម៉ឹត ចយ	០០១ ០៤៦	នាយរងសេនាធិការ	កងពលតូចលេខ ២១
៩-	វរសេនីយ៍ទោ	ឡុង គឹង	០០៣ ០៥៤	នាយរងសេនាធិការ	កងពលតូចលេខ ២១
១០-	វរសេនីយ៍ទោ	អ៊ុន ពៅ	០០៣ ០៥៥	មេបញ្ជាការវរសេនាតូចលេខ២១២	កងពលតូចលេខ ២១
១១-	វរសេនីយ៍ទោ	ផាត សារ៉ុន	០០៣ ០៥២	មេបញ្ជាការវរសេនាតូចលេខ២១៣	កងពលតូចលេខ ២១
១២-	វរសេនីយ៍ទោ	ពេជ្រ សារិទ្ធិ	០០១ ០៤១	មេបញ្ជាការវរសេនាតូចលេខ២១៤	កងពលតូចលេខ ២១
១៣-	វរសេនីយ៍ត្រី	សេង សុផាត	០០៤ ១៨១	នាយការិយាល័យទី១	កងពលតូចលេខ ២១
១៤-	វរសេនីយ៍ត្រី	អ៊ុក ចន្ថា	០០៤ ១៨១	នាយការិយាល័យទី២	កងពលតូចលេខ ២១
១៥-	វរសេនីយ៍ត្រី	ស៊ុន ចន្ទ្ធារ៉ា	០០៥ ៨៤៧	នាយការិយាល័យទី៤	កងពលតូចលេខ ២១
១៦-	វរសេនីយ៍ត្រី	ឯល សំអាត	០០៣ ០៦២	នាយការិយាល័យទី៥	កងពលតូចលេខ ២១
១៧-	វរសេនីយ៍ត្រី	ផន សារ៉ុន	០០៤ ១៨៤	នាយការិយាល័យហិរញ្ញ	កងពលតូចលេខ ២១
១៨-	វរសេនីយ៍ត្រី	ឈឹម ឃួរ	០០៥ ៨៣៤	នាយហិរញ្ញវត្ថុ	កងពលតូចលេខ ២១
១៩-	វរសេនីយ៍ត្រី	កែម ធឿន	០០៣ ០៨២	មេបញ្ជាការរង វរសេនាតូចលេខ ២១១	កងពលតូចលេខ ២១
២០-	វរសេនីយ៍ត្រី	ម៉ៅ មឿន	០០៤ ១៨៥	មេបញ្ជាការរង វរសេនាតូចលេខ ២១២	កងពលតូចលេខ ២១
២១-	វរសេនីយ៍ត្រី	ផន យឿន	០០៤ ១៨៥	មេបញ្ជាការរង វរសេនាតូចលេខ ២១២	កងពលតូចលេខ ២១
២២-	វរសេនីយ៍ត្រី	ហ៊ួត នី	០០៤ ១៨៦	មេបញ្ជាការរង វរសេនាតូច ២១២ និងជានាយសេនាធិការ	កងពលតូចលេខ ២១

២៣-	វរសេនីយ៍ត្រី	ខេង សារុន	០០២ ៧៧០	មេបញ្ជាការរង វរសេនាតូចលេខ ២១៣	កងពលតូចលេខ ២១
២៤-	វរសេនីយ៍ត្រី	ឈួន ម៉ុនធឿន	០០៤ ១៨៩	មេបញ្ជាការរង វរសេនាតូចលេខ ២១៣	កងពលតូចលេខ ២១
២៥-	វរសេនីយ៍ត្រី	ភ្លុច ធី	០០៤ ១៨៨	មេបញ្ជាការរង វរសេនាតូច ២១៣ និងជានាយសេនាធិការ	កងពលតូចលេខ ២១
២៦-	វរសេនីយ៍ត្រី	អ៊ុក សំអុន	០០៣ ០៧៩	មេបញ្ជាការរង វរសេនាតូចលេខ ២១៤	កងពលតូចលេខ ២១
២៧-	វរសេនីយ៍ត្រី	ចាន់ សុខន	០០៤ ១៩០	មេបញ្ជាការរង វរសេនាតូច ២១៥ និងជានាយសេនាធិការ	កងពលតូចលេខ ២១
២៨-	អនុសេនីយ៍ឯក	ឆន់ សុជាតិ	០០៩ ៨៣៣	នាយរងសេនាធិការដ្ឋាន	កងពលតូចលេខ ២១
២៩-	អនុសេនីយ៍ឯក	ទ៉ែន ចាន្លី	០០៤ ៤៧៩	នាយរងការិយាល័យទី១	កងពលតូចលេខ ២១
៣០-	អនុសេនីយ៍ឯក	ទ៉ែន រី	០១៨ ៦៨៤	នាយរងការិយាល័យទី៣	កងពលតូចលេខ ២១
៣១-	អនុសេនីយ៍ឯក	ម៉ឿន ម៉េត	០១៨ ៦៨៨	នាយរងការិយាល័យទី៤	កងពលតូចលេខ ២១
៣២-	អនុសេនីយ៍ឯក	ស្រី សំ	០០៩ ៨៤៨	នាយរងការិយាល័យទី៥	កងពលតូចលេខ ២១
៣៣-	អនុសេនីយ៍ឯក	គឹម ទ៉ុន	០០៩ ៨៣៥	នាយផ្នែកវិស្វកម្ម	កងពលតូចលេខ ២១
៣៤-	អនុសេនីយ៍ឯក	ឆំ សុខា	០០៩ ៨៣៧	នាយផ្នែកសុខាភិបាល	កងពលតូចលេខ ២១
៣៥-	អនុសេនីយ៍ឯក	ទ៉ែន រ៉ាម៉ុច	០០៩ ៨៤៧	នាយផ្នែកគលានដ្ឋាន	កងពលតូចលេខ ២១
៣៦-	អនុសេនីយ៍ឯក	អ៊ូ នី	០១៨ ៦៦៧	មេបញ្ជាការអនុសេនាធំការពារ	កងពលតូចលេខ ២១
៣៧-	អនុសេនីយ៍ឯក	សេង រ៉េន	០១១ ៣៤៣	មេបញ្ជាការអនុសេនាធំស៊ើបការ	កងពលតូចលេខ ២១
៣៨-	អនុសេនីយ៍ឯក	ស៊ុន សារឿន	០០៩ ៨៥១	មេបញ្ជាការអនុសេនាធំបញ្ជូនសារ	កងពលតូចលេខ ២១
៣៩-	អនុសេនីយ៍ឯក	ហ៊ឹម រិទ្ធិ	០០៩ ៨៤៤	មេបញ្ជាការអនុសេនាធំ[illegible]ជញ្ជូន	កងពលតូចលេខ ២១
៤០-	អនុសេនីយ៍ឯក	គី សុធន់	០០៩ ៨៥៣	មេបញ្ជាកា[illegible]នុសេនាធំកាំភ្លើងធំ	កងពលតូចលេខ ២១
៤១-	អនុសេនីយ៍ឯក	នន សុផល	០០៩ ៨៥២	[illegible]បញ្ជាការអនុសេនាធំវិស្វកម្ម	កងពលតូចលេខ ២១
៤២-	អនុសេនីយ៍ឯក	ម៉ុល សុធី	០១៨ ៦៤០	ជំនួយការរថក្រោះ រថពាសដែក	កងពលតូចលេខ ២១
៤៣-	អនុសេនីយ៍ឯក	[illegible]	០១៨ ៦៩៥	នាយរងហិរញ្ញវត្ថុ	កងពលតូចលេខ ២១
	អនុសេនីយ៍ឯក	ឈុយ ផា	០០៩ ៧៨១	មេបញ្ជាការគាំទ្រវរសេនាតូច ២១៤	កងពលតូចលេខ ២១
៤៥-	អនុសេនីយ៍ទោ	ហ៊ុន ឌីណា	០១៨ ៦៧៨	នាយរងការិយាល័យទី២	កងពលតូចលេខ ២១

៤៦- អនុសេនីយ៍ទោ **ស្រ៊ុន គន្ធុល** ០១២ ៨៧៦ នាយរងការិយាល័យទី២ កងពលតូចលេខ ២១

៤៧- អនុសេនីយ៍ទោ **ជួង ដារ៉ារិទ្ធិ** ០១៨ ៦៧១ នាយរងហ្វឹកហ្វឺន កងពលតូចលេខ ២១

៤៨- អនុសេនីយ៍ទោ **ខ្វាង ម៉ុនណារ៉ា** ០១៨ ៦៨៦ មេបញ្ជាការរងការពារអាកាស កងពលតូចលេខ ២១

៤៩- អនុសេនីយ៍ទោ **ស្រាក់ សុធី** ០១៨ ៦៩៩ មេបញ្ជាការរងអនុសេនាធំស៊ើបការ កងពលតូចលេខ ២១

ខ- មេដាយប្រាក់ការងារជូនបុគ្គល :

១- វរសេនីយ៍ត្រី **ពេជ្រ ឈុន** ០០៣ ០៦៣ មេបញ្ជាការរងវរសេនាតូច ២១៤ កងពលតូចលេខ ២១

២- វរសេនីយ៍ត្រី **ទឹម សំរេច** ០០៩ ៨៤៣ មេបញ្ជាការរងវរសេនាតូច ២១៤ កងពលតូចលេខ ២១

៣- អនុសេនីយ៍ឯក **អ៊ិន សុផាន** ០១១ ៣៤៤ មេបញ្ជាការរងអនុសេនាធំលេខ៣ វរសេនាតូច ២១២ កងពលតូចលេខ ២១

៤- អនុសេនីយ៍ឯក **សៀប សារឿន** ០០៩ ៨៦៤ មេបញ្ជាការរងអនុសេនាធំលេខ២ វរសេនាតូច ២១២ កងពលតូចលេខ ២១

៥- អនុសេនីយ៍ឯក **ឈិន តឿន** ០០៩ ៨៦៣ មេបញ្ជាការរងអនុសេនាធំលេខ១ វរសេនាតូច ២១២ កងពលតូចលេខ ២១

៦- អនុសេនីយ៍ឯក **ស្រាក់ ខួរ** ០០៩ ៨៦១ មេបញ្ជាការរងអនុសេនាធំគាំទ្រ វរសេនាតូច ២១២ កងពលតូចលេខ ២១

៧- អនុសេនីយ៍ឯក **ស៊ុម ហ៊ាវ** ០០៩ ៨៧៥ មេបញ្ជាការរងអនុសេនាធំគាំទ្រ វរសេនាតូច២១៣ កងពលតូចលេខ ២១

៨- អនុសេនីយ៍ឯក **នួន ឌៃ** ០០៩ ៨៧៣ មេបញ្ជាការរងអនុសេនាធំលេខ២ វរសេនាតូច ២១៣ កងពលតូចលេខ ២១

៩- អនុសេនីយ៍ឯក **សោម គីមលី** ០០៩ ៨៧៨ មេបញ្ជាការរងអនុសេនាធំលេខ៣ វរសេនាតូច ២១៣ កងពលតូចលេខ ២១

១០- អនុសេនីយ៍ឯក **ទ៉ាន់ សាម៉ាត** ០០៩ ៨៧០ មេបញ្ជាការរងអនុសេនាធំលេខ១ វរសេនាតូច ២១៤ កងពលតូចលេខ ២១

១១- អនុសេនីយ៍ឯក **យ៉ិន ចយ** ០០៩ ៨៦៦ មេបញ្ជាការរងអនុសេនាធំលេខ២ វរសេនាតូច២១៤ កងពលតូចលេខ ២១

១២- អនុសេនីយ៍ឯក **ឡឹម សារ៉េន** ០១៨ ៧២៨ មេបញ្ជាការរងអនុសេនាធំលេខ៣ វរសេនាតូច ២១៤ កងពលតូចលេខ ២១

១៣- អនុសេនីយ៍ឯក **ចន្ថា ធីរៈ** ០១៨ ៧៤០ នាយរងការិយាល័យទី៣ កងពលតូចលេខ ២១

១៤- អនុសេនីយ៍ឯក **នាយ សុភឿន** ០០៩ ៨៥៤ នាយរងការិយាល័យហ្វឹកហ្វឺន កងពលតូចលេខ ២១

១៥- អនុសេនីយ៍ឯក **នួន ទឿន** ០០៩ ៨៣៨ ជំនួយការឯកទេស កងពលតូចលេខ ២១

១៦- អនុសេនីយ៍ឯក **កែម រី** ០១៨ ៦៨៥ ស-៥៨០ កងពលតូចលេខ ២១

១៧- អនុសេនីយ៍ទោ **អ៊ូ សាជន** ០១៨ ៦៧៣ នាយរងការិយាល័យទី១ កងពលតូចលេខ ២១

១៨- អនុសេនីយ៍ទោ **នេព. ណារិទ្ធ** ០១៨ ៧២៥ ជំនួយការចំណាត់ពត៌មាន កងពលតូចលេខ ២១

១៩- អនុសេនីយ៍ទោ **ម៉េន សារិន** ០២៤ ៤៨០ ជំនួយការផែនការការិយាល័យទី៣ កងពលតូចលេខ ២១

២០-	អនុសេនីយ៍ទោ **អៀង សេង**	០១៨ ៦៩០	ជំនួយការស្បៀងការិយាល័យទី៤	កងពលតូចលេខ ២១
២១-	អនុសេនីយ៍ទោ **សៅ ស៊ាន**	០១៨ ៦៩៣	នាយរងការិយាល័យទី៥	កងពលតូចលេខ ២១
២២-	អនុសេនីយ៍ទោ **ស្វាយ សំខាន់**	០១៨ ៧០៨	នាយរងពិលានដ្ឋាន	កងពលតូចលេខ ២១
២៣-	អនុសេនីយ៍ទោ **ជា យឹម**	០១៨ ៦៦៣	ជំនួយការបុគ្គលិកលេខាធិការដ្ឋាន	កងពលតូចលេខ ២១
២៤-	អនុសេនីយ៍ទោ **កែវ សុម៉ាលី**	០១៤ ៤៨៩	ជំនួយការបច្ចេកទេស និងឯកទេស	កងពលតូចលេខ ២១
២៥-	អនុសេនីយ៍ទោ **ស៊ុំ ស៊ាច**	០១៨ ៧៣០	មេបញ្ជាការរងអនុសេនាធំការពារអាកាស	កងពលតូចលេខ ២១
២៦-	អនុសេនីយ៍ទោ **មាឃ នុន**	០១៨ ៦៩៧	មេបញ្ជាការរងអនុសេនាធំកាំភ្លើងធំ	កងពលតូចលេខ ២១
២៧-	អនុសេនីយ៍ទោ **ស៊ិន ពៀន**	០១៨ ៧០៦	មេបញ្ជាការរងអនុសេនាធំវិស្វកម្ម	កងពលតូចលេខ ២១
២៨-	អនុសេនីយ៍ទោ **ឥន សាវឿន**	០២៨ ៤៧៧	មេបញ្ជាការរងអនុសេនាធំដឹកជញ្ជូន	កងពលតូចលេខ ២១
២៩-	អនុសេនីយ៍ទោ **សុខ ឡេង**	០២៨ ៣០៧	ជំនួយការហិរញ្ញវត្ថុ	កងពលតូចលេខ ២១
៣០-	អនុសេនីយ៍ទោ **នឹម សុភាន់**	០១៨ ៧៩២	ជំនួយការបុគ្គលិកវរសេនាតូច២១២	កងពលតូចលេខ ២១
៣១-	អនុសេនីយ៍ទោ **គី នុន**	០១៨ ៧២៩	មេបញ្ជាការរងវរសេនាធំលេខ១ វរសេនាតូច២១២	កងពលតូចលេខ ២១
៣២-	អនុសេនីយ៍ទោ **ពេជ្រ សំបូរ**	០១៨ ៧៣៧	មេបញ្ជាការរងវរសេនាធំលេខ១ វរសេនាតូច២១២	កងពលតូចលេខ ២១
៣៣-	អនុសេនីយ៍ទោ **ជា សុវណ្ណារ៉ុង**	០១៨ ៧១០	ជំនួយការបុគ្គលិកវរសេនាតូច ២១៣	កងពលតូចលេខ ២១
៣៤-	អនុសេនីយ៍ទោ **អឿន អន**	០១៨ ៧៦៣	មេបញ្ជាការរងអនុសេនាធំលេខ១ វរសេនាតូច ២១៣	កងពលតូចលេខ ២១
៣៥-	អនុសេនីយ៍ទោ **ឈឹម ចាញ**	០១៨ ៦៧៧	ជំនួយការបុគ្គលិកវរសេនាតូច២១៤	កងពលតូចលេខ ២១
៣៦-	អនុសេនីយ៍ទោ **ចេង សំអុន**	០១២ ៨៦៥	ជំនួយការប្រតិបត្តិការសឹក វរសេនាតូចលេខ ២១៤	កងពលតូចលេខ ២១
៣៧-	អនុសេនីយ៍ត្រី **យូ ស៊ីណាត**	០២៨ ៥៤៤	ជំនួយការសរសើរ និងទណ្ឌកម្ម ការិយាល័យទី១	កងពលតូចលេខ ២១
៣៨-	អនុសេនីយ៍ត្រី **សន សុខឿន**	០២៨ ៤៨៥	ជំនួយការតែងតាំង ការិយាល័យទី១	កងពលតូចលេខ ២១
៣៩-	អនុសេនីយ៍ត្រី **ពូល ទេឃឿន**	០២៨ ៥៤៩	ជំនួយការបុគ្គលិក ការិយាល័យទី១	កងពលតូចលេខ ២១
៤០-	អនុសេនីយ៍ត្រី **អ៊ុច ចាន់រ៉ា**	០២៨ ៤៦៧	ជំនួយការស្បៀងការិយាល័យទី៤	កងពលតូចលេខ ២១
៤១-	អនុសេនីយ៍ត្រី **យិន សារុន**	០២៨ ៤៧៥	ជំនួយការអគារ	កងពលតូចលេខ ២១
៤២-	អនុសេនីយ៍ត្រី **អ៊ិន សុធា**	០៣០ ១៦០	ជំនួយការហិរញ្ញវត្ថុ	កងពលតូចលេខ ២១
៤៣-	អនុសេនីយ៍ត្រី **ហ៊ួន ផល្លី**	០២៨ ៤៦៥	មេបញ្ជាការអនុសេនាតូច អនុសេនាធំស៊ើបការ	កងពលតូចលេខ ២១

៤៤-	អនុសេនីយ៍ត្រី **ម៉ាន់. ចន្ថា**	០៤១ ០៨៨	មេបញ្ជាការអនុសេនាតូច អនុសេនាធំបញ្ជូនសារ	កងពលតូចលេខ ២១
៤៥-	អនុសេនីយ៍ត្រី **ថោង រី**	០៤១ ០៨៥	មេបញ្ជាការអនុសេនាតូច អនុសេនាធំវិស្វកម្ម	កងពលតូចលេខ ២១
៤៦-	អនុសេនីយ៍ត្រី **ស៊ិន ចិមុល**	០២៨ ៥៥២	ជំនួយការស្បៀងវរសេនាតូច ២១៣	កងពលតូចលេខ ២១
៤៧-	អនុសេនីយ៍ត្រី **អ៊ុំ ចន្ថា**	០៤១ ១៦៩	មេបញ្ជាការអនុសេនាតូចស៊ើបការ វរសេនាតូច ២១៣	កងពលតូចលេខ ២១
៤៨-	នាយចំណោង **ម៉ៅ សែម**	០៥៧ ០៨៤	ជំនួយការបូកសរុបការិយាល័យទី៣	កងពលតូចលេខ ២១

គ-មេដាយសិរិទ្ធការងារជូនបុគ្គល :

១-	អនុសេនីយ៍ទោ **ចន្ទ ស៊ីថា**	០១៨ ៦៧៤	ជ-សិក្សាគំរោង ការិយាល័យទី១	កងពលតូចលេខ ២១
២-	អនុសេនីយ៍ទោ **ជន ថូត**	០១៨ ៦៩១	ជ-សញ្ញាវុធ ការិយាល័យទី១	កងពលតូចលេខ ២១
៣-	អនុសេនីយ៍ទោ **ចាំ អ៊ិត**	០១២ ៨៦៦	ជ-បញ្ជូនសារ	កងពលតូចលេខ ២១
៤-	~~អនុសេនីយ៍ទោ **អ៊ុំ សារិន**~~	~~០១៨ ៧១៧~~	មេបញ្ជាការរងអនុសេនាធំការពារ	កងពលតូចលេខ ២១
៥-	អនុសេនីយ៍ទោ **សៀម ណា**	០១៨ ៧៣៤	ជ-ហ្វឹកហ្វឺន វរសេនាតូច ២១២	កងពលតូចលេខ ២១
៦-	អនុសេនីយ៍ទោ **គង ចន្ទ**	០១៨ ៧៣៥	ជ-បើកបរវរសេនាតូច ២១២	កងពលតូចលេខ ២១
៧-	អនុសេនីយ៍ទោ **សុខ ផល**	០១៨ ៧៣២	មេបញ្ជាការរងអនុសេនាធំគាំទ្រ វរសេនាតូច ២១២	កងពលតូចលេខ ២១
៨-	អនុសេនីយ៍ទោ **ចាន់ ញ៉ី**	០១៨ ៧២៦	ជ-ប្រតិបត្តិការសឹក វរសេនាតូច ២១២	កងពលតូចលេខ ២១
៩-	អនុសេនីយ៍ទោ **ទុំ ពុធ**	០១៨ ៧៣៦	មេបញ្ជាការរងអនុសេនាលេខ៣ វរសេនាតូច ២១២	កងពលតូចលេខ ២១
១០-	អនុសេនីយ៍ទោ **ឈឹម ផាំ**	០១៨ ៧៥៧	ជ-ហ្វឹកហ្វឺន វរសេនាតូច ២១៣	កងពលតូចលេខ ២១
១១-	អនុសេនីយ៍ទោ **ខៀវ សេង**	០១៨ ៧៥៣	ជ-បញ្ជូនសារ វរសេនាតូច ២១៣	កងពលតូចលេខ ២១
១២-	អនុសេនីយ៍ទោ **ម៉ារ ចន្ថា**	០១៨ ៧៦២	មេបញ្ជាការរងអនុសេនាធំគាំទ្រ វរសេនាតូច ២១៣	កងពលតូចលេខ ២១
១៣-	អនុសេនីយ៍ទោ **គួច សុផាត**	០១៨ ៧៦១	មេបញ្ជាការរងអនុសេនាលេខ២ វរសេនាតូច ២១៣	កងពលតូចលេខ ២១
១៤-	អនុសេនីយ៍ទោ **ចាន្ទ ខ្សេម**	០១៨ ៧៤២	ជ-វិស្វកម្ម វរសេនាតូចលេខ ២១៤	កងពលតូចលេខ ២១
១៥-	អនុសេនីយ៍ទោ **សាន់ ធន**	០១៨ ៧៤១	ជ-ចលនបុត្តម្ភ វរសេនាតូចលេខ ២១៤	កងពលតូចលេខ ២១
១៦-	អនុសេនីយ៍ទោ **សុន្ទ ពេញ**	០១៨ ៧៤៨	មេបញ្ជាការរង អនុសេនាធំលេខ១ វរសេនាតូចលេខ ២១៤	កងពលតូចលេខ ២១
១៧-	អនុសេនីយ៍ទោ **នួន .ស៊ាន**	០១៨ ៧៤៦	មេបញ្ជាការរង អនុសេនាធំលេខ៣ វរសេនាតូចលេខ ២១៤	កងពលតូចលេខ ២១

១៨-	អនុសេនីយ៍ទោ អ៊ុក សុខុម	០១៨ ៧៤៣	មេបញ្ជាការរង អនុសេនាធំលេខ២ វរសេនាតូចលេខ ២១៤	កងពលតូចលេខ ២១
១៩-	អនុសេនីយ៍ត្រី ចៅ ម៉ាឌិត	០២៨ ៥៥០	ជ-បូកសរុក ក-៣	កងពលតូចលេខ ២១
២០-	អនុសេនីយ៍ត្រី ឯម សំបូរ	០៣៦ ៦៩៧	ជ-គ្រឿងចក្រការិយាល័យទី៤	កងពលតូចលេខ ២១
២១-	អនុសេនីយ៍ត្រី ជា ជួន	០២៨ ៤៦០	ជ-ស្មៀងលេខាធិការដ្ឋាន	កងពលតូចលេខ ២១
២២-	អនុសេនីយ៍ត្រី ស្រី ឡឿន	០៤៧ ០២៤	ជ-បំភ័នអក្ខរៈ	កងពលតូចលេខ ២១
២៣-	អនុសេនីយ៍ត្រី ស្ងួន សុខា	០២៨ ៤៧០	ពេទ្យ មធ្យម	កងពលតូចលេខ ២១
២៤-	អនុសេនីយ៍ត្រី ឃឹម ឃី	០២៨ ៤៨០	មេបញ្ជាការអនុសេនាតូច អនុសេនាធំកាំភ្លើងធំ	កងពលតូចលេខ ២១
២៥-	អនុសេនីយ៍ត្រី សៀង អួន	០៤១ ១៧១	មេបញ្ជាការអនុសេនាតូច អនុសេនាធំការពារអាកាស	កងពលតូចលេខ ២១
២៦-	អនុសេនីយ៍ត្រី អ៊ុច ឡឿន	០២៨ ៤៨២	មេបញ្ជាការអនុសេនាតូច អនុសេនាធំ ស៊ើការ	កងពលតូចលេខ ២១
២៧-	អនុសេនីយ៍ត្រី ទេព គន	០២៨ ៤៨៦	មេបញ្ជាការអនុសេនាតូច អនុសេនាធំបញ្ជូនសារ	កងពលតូចលេខ ២១
២៨-	អនុសេនីយ៍ត្រី ប្រាក់ អ៊ុន	០៤១ ១០១	មេបញ្ជាការអនុសេនាតូច អនុសេនាធំបញ្ជូនសារ	កងពលតូចលេខ ២១
២៩-	អនុសេនីយ៍ត្រី ខត្យ ថេត	០២៨ ៥៤៦	មេបញ្ជាការអនុសេនាតូច អនុសេនាធំដឹកជញ្ជូន	កងពលតូចលេខ ២១
៣០-	អនុសេនីយ៍ត្រី រស់ សារិន	០២៨ ៤៦២	មេបញ្ជាការអនុសេនាតូច អនុសេនាធំដឹកជញ្ជូន	កងពលតូចលេខ ២១
៣១-	អនុសេនីយ៍ត្រី ម៉ម ម៉ុម	០៤១ ០៥៨	មេបញ្ជាការអនុសេនាតូច អនុសេនាធំវិស្វកម្ម	កងពលតូចលេខ ២១
៣២-	អនុសេនីយ៍ត្រី អ៊ុង សុខន	០២៨ ៤៨៥	មេបញ្ជាការអនុសេនាតូច អនុសេនាតូចលេខ ២១១	កងពលតូចលេខ ២១
៣៣-	អនុសេនីយ៍ត្រី ស៊ិន បូរិន្ទី	០៥៧ ១៦៨	ជ-ចលនូបត្ថម្ភ វរសេនាតូចលេខ ២១២	កងពលតូចលេខ ២១
៣៤-	អនុសេនីយ៍ត្រី សៀង សារិន	០៤១ ៣០១	ជ-ចលនូបត្ថម្ភ វរសេនាតូចលេខ២១២	កងពលតូចលេខ ២១
៣៥-	អនុសេនីយ៍ត្រី ស សារ៉េន	០៥៧ ១៣៤	ជ-ហិរញ្ញវត្ថុ វរសេនាតូចលេខ ២១៣	កងពលតូចលេខ ២១
៣៦-	អនុសេនីយ៍ត្រី សោម សម្បត្តិ	០២៨ ៥២៦	ជ-ហិរញ្ញវត្ថុ វរសេនាតូចលេខ ២១៣	កងពលតូចលេខ ២១
៣៧-	អនុសេនីយ៍ត្រី សុខ ចន្ទ្រា	០២៨ ៥៥៩	មេបញ្ជាការអនុសេនាតូច អនុសេនាធំគាំទ្រ វរសេនាធំ ២១៣	កងពលតូចលេខ ២១
៣៨-	នាយចំណង់ ស្មូត្រ សុផារ៉ត	០៥៧ ០៨៧	ជ-សោធន ឯកសារ ការិយាល័យទី១	កងពលតូចលេខ ២១
៣៩-	នាយចំណង់ ហែម សារ៉ា	០៥៧ ០៧៩	ជ-ចាត់ការទូទៅ លេខាធិការដ្ឋាន	កងពលតូចលេខ ២១
៤០-	នាយចំណង់ សេម ថារិទ្ធី	១៥៧ ១៨៩	ជ-ហិរញ្ញវត្ថុ	កងពលតូចលេខ ២១

៤១-	ព្រិន្ទបាលឯក	**ឃួន មករា**	០៦៣ ៨៥៨	មេបញ្ជាការអនុសេនាតូច អនុសេនាធំដឹកជញ្ជូន	កងពលតូចលេខ ២១
៤២-	ព្រិន្ទបាលទោ	**យ៉េង សាទ័ន្ត**	១៣៩ ៣១៣	មេក្រុមអនុសេនាតូចលេខ១ អនុសេនាធំបញ្ជូនសារ	កងពលតូចលេខ ២១
៤៣-	ព្រិន្ទបាលទោ	**ទឹម នាង**	១៦៨ ២៣៥	មេក្រុមអនុសេនាតូចលេខ១ អនុសេនាធំវិស្វកម្ម	កងពលតូចលេខ ២១
៤៤-	ពលបាលឯក	**នួន ចិន្ត**	១៣៩ ២៩១	ជំ-ពេទ្យ អនុសេនាធំ ស៊ើបការ	កងពលតូចលេខ ២១
៤៥-	ពលបាលឯក	**ឡាច ខែម**	១៣៩ ២៦៨	រងក្រុមអនុសេនាតូចលេខ៣ អនុសេនាធំកាំភ្លើងធំ	កងពលតូចលេខ ២១
៤៦-	នាយឯក	**ពុធ កុសល**	១១៤ ០០១	ពលទាហានអនុសេនាធំការពារអាកាស	កងពលតូចលេខ ២១
៤៧-	នាយឯក	**ម៉ី ធីម**	១១៨ ៧៥០	ពលទាហានអនុសេនាធំការពារអាកាស	កងពលតូចលេខ ២១

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣២ សសរ

សេចក្ដីសម្រេច

ស្ដីពី

ការបង្កើតគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីទាតយកដីធ្វើកម្មសិទ្ធិ នៅតាមបណ្ដាខេត្ត-ក្រុងមួយចំនួន នៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

ប្រការ១.-

បង្កើតគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រានដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើកម្មសិទ្ធិ នៅតាមបណ្តាខេត្ត-ក្រុងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ÷

១- ឯកឧត្តម **ចំន្ទ សារុន**	រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ		ប្រធាន
២- ឯកឧត្តម **ឯម សំអាន**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ		អនុប្រធាន
៣- ឯកឧត្តម **ម៉ុន អ៊ុយ**	អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី		សមាជិក
៤- ឯកឧត្តម **ម៉ុន សំ**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ		សមាជិក
៥- ឯកឧត្តម **វន្ធ័ សារិន**	អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់		សមាជិក
៦- ឯកឧត្តម **ធឹក គ្រឿនចុន្ថា**	អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន		សមាជិក
៧- ឯកឧត្តម **អ៊ុំ ជិន**	អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌		សមាជិក
៨-ឯកឧត្តមឧត្តមសេនីយ៍ឯក **ខា នារា**	ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ		សមាជិក
៩- ឯកឧត្តមឧត្តមសេនីយ៍ទោ **ហ៊ាន់ ណាយ**	អគ្គស្នងការដ្ឋាននគរបាលជាតិ		សមាជិក
១០- ឯកឧត្តម **តិច ចំន្ទតារា**	អគ្គនាយកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា		សមាជិក
១១- លោកវរៈសេនីយ៍ឯក **ទ្រាក់ សិទ្ធិ**	បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស		សមាជិក
១២- ឯកឧត្តម អភិបាលខេត្ត-ក្រុងសាមី			សមាជិក
១៣- ឯកឧត្តម **ឌី សុគន្ធ**	ប្រធានរដ្ឋបាលព្រៃឈើ		អគ្គលេខាធិការប្រតិបត្តិ

ប្រការ២.-

គណៈកម្មាធិការជាតិនេះ មានតួនាទី និងភារកិច្ចដូចតទៅ ÷

១- រៀបចំ និងអនុវត្តផែនការសកម្មភាពផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានដែលពាក់ព័ន្ធទៅនឹងដីព្រៃឈើគ្រប់ប្រភេទ ។

២- ត្រួតពិនិត្យ និងស្រាវជ្រាវដល់មូលដ្ឋានដែលមានការកាប់រានដីព្រៃខុសច្បាប់ ក្នុងគោលបំណងធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ឬទុកធ្វើអាជីវកម្មបន្ត ។

៣- ចាត់វិធានការទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបឱ្យទាន់ពេលវេលា នូវរាល់ការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើគ្រប់ប្រភេទ ។

៤- ធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងសហគមន៍អ្នកផ្តល់ជំនួយ ដើម្បីជំរុញ និងគាំទ្រការងារនេះ ។

៥- ធ្វើរបាយការណ៍ និងលើកអនុសាសន៍ ជូនរាជរដ្ឋាភិបាលលើការអនុវត្តផែនការសកម្មភាព ។

៦- បង្កើតយន្តការអនុវត្តតាមខេត្ត-ក្រុងនីមួយៗតាមការចាំបាច់នូវអនុគណៈកម្មាធិការមួយ ដែលមានឯកឧត្តមអភិបាលខេត្ត-ក្រុងជាប្រធានដើម្បីបំពេញការងារអនុវត្តភារកិច្ចនានាដែលគណៈកម្មាធិការជាតិផ្តល់អោយ ។

ប្រការ៣.-

សមាជិកគណៈកម្មាធិការជាតិ ត្រូវចូលរួមទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ចរបស់ខ្លួន និងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ៤.-

គណៈកម្មាធិការជាតិនេះ មានអគ្គលេខាធិការដ្ឋានប្រតិបត្តិនៅរដ្ឋបាលព្រៃឈើ ដែលមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ដើម្បីអនុវត្តភារកិច្ច និងសំរួលការងាររបស់ខ្លួន ។

ប្រការ៥.-

រាល់ការចំណាយរបស់អគ្គលេខាធិការដ្ឋាន ជាបន្ទុករបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

ប្រការ៦.-

គណៈកម្មាធិការជាតិ មានសិទ្ធិចាត់តាំងក្រុមការងារផ្សេងទៀតតាមការចាំបាច់ ។

ប្រការ៧.-

អនុគណៈកម្មការដែលជាយន្តការអនុវត្តមានសិទ្ធិប្រើប្រាស់ត្រារបស់អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ។

ប្រការ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងប្រការ ១ នៃសេចក្តីសំរេចនេះ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧ សសរ

សេចក្តីសំរេច

ស្តីពី

ការបង្កើតក្រុមការងារសំរាប់រៀបចំ និង ពិនិត្យ លើកិច្ចសន្យា ជួលដីឆ្នេរហាវ៉ៃ ទីក្រុងព្រះសីហនុ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ១ : - ត្រូវបានបង្កើតក្រុមការងារសំរាប់រៀបចំ និង ពិនិត្យលើកិច្ចសន្យាជួលដីឆ្នេរហាវ៉ៃ ក្រុងព្រះសីហនុ អោយទៅក្រុមហ៊ុន Emario Shonan Marine Corporation ដើម្បីធ្វើការវិនិយោគវិស័យទេសចរណ៍ ហៅកាត់ថា "ក្រុមការងារ" ។

ប្រការ២ : - ក្រុមការងារមានសមាសភាពដូចខាងក្រោម :

- តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
- តំណាងក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់	សមាជិក
- តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន	សមាជិក
- តំណាងក្រសួងទេសចរណ៍	សមាជិក
- តំណាង ក្រសួងបរិស្ថាន	សមាជិក
- តំណាង រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល	សមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
- តំណាង សាលាក្រុងព្រះសីហនុ	សមាជិក

<u>ប្រការ៣</u> : - ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

- រៀបចំកិច្ចសន្យាជួលដីឆ្នេរហាវ៉ៃ ក្រុងព្រះសីហនុ
- ពិនិត្យ និង ចរចារលើថ្លៃឈ្នួលដីអោយបានសមស្រប
- ចុះពិនិត្យនិងវាស់វែងលើទីតាំង ភូមិសាស្ត្រតំបន់ដែលត្រូវជួល
- វាយតំលៃផលប៉ះពាល់ដល់បរិស្ថាន
- ពិនិត្យលើគំរោងសាងសង់របស់ក្រុមហ៊ុន អោយស្របតាមប្លង់នគរូបនីយកម្ម

<u>ប្រការ៤</u> : - សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

<u>ប្រការ៥</u> : - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួង សាធារណការ និង ដឹកជញ្ជូន ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី និងស្ថាប័នដទៃទៀតដែលមានឈ្មោះក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន:</u>

- ក្រសួងព្រះបរម្យរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប "
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤ សសរ

សេចក្ដីសំរេច

ស្ដីពី

ការបង្កើតក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៩៩៦/ ១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- តាមការចាំបាច់ចំពោះមុខរបស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១: ត្រូវបានបង្កើតក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ដែលមានសមាសភាព ដូចតទៅ :

១-	ឯកឧត្ដម	**វ៉េង សេរីវុឌ្ឍ**	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍	ប្រធាន
២-	ឯកឧត្ដម	**ថោង ខុន**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធានប្រចាំការ
៣-	ឯកឧត្ដម	**ទី ចន្ទផល**	អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	អនុប្រធាន
៤-	ឯកឧត្ដម	**ជុច កឿន**	អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
៥-	ឯកឧត្ដម	**ឡុង វិសាលោ**	អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក

៦-	ឯកឧត្តម	**ញាណ ឡេង**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៧-	ឯកឧត្តម	**ចឹក គ្រឿនឧត្តា**	អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
៨-	ឯកឧត្តម	**វ៉ែត សារិន**	អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៩-	ឯកឧត្តម	**មាស គឹមសុវ៉ារ៉ូ**	អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ	សមាជិក
១០-	ឯកឧត្តម	**ទ៊េង សាខុន**	អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
១១-	ឯកឧត្តម	**ហ៊ុល លឹម**	អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១២-	ឯកឧត្តម	**សៅ សុខុន**	អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
១៣-	ឯកឧត្តម	**គីម ស៊ុថន**	អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
១៤-	ឯកឧត្តម	**ថាច់ ផែន**	អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន	សមាជិក
១៥-	ឯកឧត្តម	**ស៊ឹម សួង**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១៦-	ឯកឧត្តម	**អ៊ុក សារមេត្ត**	អគ្គនាយករងអាជ្ញាធរអប្សរា	សមាជិក
១៧-	លោក	**ង៉ ឡេងហួង**	អគ្គនាយករង នៃធនាគារអភិវឌ្ឍន៍ជនបទ	សមាជិក

ប្រការ ២: ក្រុមការងារទេសចរណ៍ សំរាប់កាត់បន្ថយភាពក្រីក្រ មានមុខងារ និងភារកិច្ចដូចតទៅ :

- អនុវត្ត និងសំរបសំរួលតាមគោលនយោបាយ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ដោយសហការជាមួយក្រសួង ស្ថាប័ពាក់ព័ន្ធនានា ដើម្បីសិក្សាអំពីទំនាក់ទំនងរវាង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព ដោយរៀបចំ កសាង គំរោងបង្ហាញការកាត់បន្ថយភាពក្រីក្រ
- បង្កើតបញ្ជីរួម និងបញ្ជីអាទិភាពនៃតំបន់អភិវឌ្ឍន៍វិស័យទេសចរណ៍ សំរាប់កាត់បន្ថយភាពក្រីក្រដែលផ្តោតទៅលើតំបន់ទីក្រុង និងជនបទ
- កសាងភូមិទេសចរណ៍មូលដ្ឋានមួយចំនួន សំរាប់ធ្វើការដកពិសោធន៍ និងធ្វើជាគំរូតាមរូបមន្តនៃចលនា "ភូមិមួយផលិតផលមួយ" ព្រមទាំងបង្កើត ពង្រឹង និងពង្រីកសហគ្រាសខ្នាតតូច និងមធ្យម
- ជំរុញ ដឹកនាំ និងគ្រប់គ្រងរាល់ការងារផ្សព្វផ្សាយព័ត៌មាន អំពីទីផ្សារទេសចរណ៍ទាំងក្នុង និងក្រៅប្រទេសលើវិស័យទេសចរណ៍ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ
- សហការជាមួយអាជ្ញាធរអប្សរាក្នុងការលើកផែនការរួម និងដោយឡែក រាល់ការអភិវឌ្ឍវិស័យទេសចរណ៍ ក្នុងតំបន់សៀមរាបអង្គរ និងតំបន់ដែលមានការពាក់ព័ន្ធ
- ស្វែងរក និងទទួលជំនួយឧបត្ថម្ភផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដើម្បីបំរើការងារខាងលើ

- ធ្វើរបាយការណ៍ ស្តីពីសកម្មភាពរបស់ក្រុមការងារ ដោយលើកសំណូមពរ និងវិធានការនានាជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យសំរេចតាមដំណាក់កាលនីមួយៗ ។

ប្រការ ៣: - ក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ក្នុងការបំពេញការងារ ។

- សមាជិកនៃក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

ប្រការ ៤: ក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅទីស្តីការក្រសួងទេសចរណ៍ ។

ប្រការ ៥: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ប្រធានអគ្គនាយកអាជ្ញាធរអប្សរា និងអភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៥ សសរ

សេចក្តីសម្រេច

ស្តីពីការផ្ទេរសិទ្ធិ

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំ រេ ច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជារដ្ឋមន្ត្រីស្តីទី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជំនួសឯកឧត្តម **ស៊ុយ សែម** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ០៨ រហូតដល់ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៤ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និង ឯកឧត្តម **ចម ប្រសិទ្ធ** ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:....០១...សរ.......

សារាចរ

ស្តីពី

ការត្រួតពិនិត្យ និង ការសំរបសំរួលក្នុងការអនុវត្តគំរោងវិនិយោគសាធារណៈ

កន្លងមក រាជរដ្ឋាភិបាលបានពិនិត្យឃើញថា ការកសាងគំរោងកម្មវិធីវិនិយោគសាធារណៈ និងការរៀបចំគំរោងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចប្រាំឆ្នាំ បានជួបប្រទះការលំបាក និងមានការយឺតយ៉ាវបណ្តាលមកពីការប្រមូលទិន្នន័យពីការអនុវត្តគំរោងមិនបានគ្រប់គ្រាន់ និងទាន់ពេលវេលា ។ ប្រការនេះ ជាហេតុធ្វើឱ្យរាជរដ្ឋាភិបាល មានការពិបាកក្នុងការរៀបចំគោលនយោបាយ ដើម្បីអភិវឌ្ឍន៍ប្រទេសលើគ្រប់វិស័យ និងធ្វើឱ្យក្រុមប្រឹក្សាអ្នកផ្តល់ជំនួយ និងកម្ចីពីបរទេស មានការលំបាកដោយសារពុំមានគំរោងជាក់លាក់ និងទិសដៅអភិវឌ្ឍន៍ប្រទេសច្បាស់លាស់ ។

ជាមួយគ្នានេះ ក្នុងការអនុវត្តគំរោងស្តារបន្ទាន់ហេដ្ឋារចនាសម្ព័ន្ធខូចខាតដោយទឹកជំនន់ឆ្នាំ ២០០០ រាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និង បណ្តាក្រសួងអនុវត្តគំរោង ព្រមទាំងភាគីផ្តល់ឥណទានសហការគ្នាបានជិតស្និទ្ធល្អប្រសើរ ដែលញ៉ាំងអោយគំរោងទាំងឡាយអនុវត្តបានទាន់ពេល ហើយក្រសួងផែនការក៏មានលទ្ធភាពរាយការណ៍ជូនរាជរដ្ឋាភិបាល ពីសកម្មភាពអនុវត្តគំរោងបានតាមកាលកំណត់ ហើយក៏ត្រូវបានចាត់ទុកជាបទពិសោធន៍មួយមានប្រសិទ្ធភាពក្នុងការអនុវត្តគំរោងវិនិយោគសាធារណៈដែរ ។

យោងតាមបទពិសោធន៍ខាងលើនេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ដូចតទៅ :

១- គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវពង្រឹងការអនុវត្តតាមស្មារតីអនុក្រឹត្យ លេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ អោយកាន់តែមានប្រសិទ្ធភាពថែមទៀត ។

២- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ និង បណ្តាក្រសួង ស្ថាប័នទាំងអស់ ត្រូវបន្តសហការជិតស្និទ្ធជាមួយគ្នា ក្នុងការអនុវត្តគំរោងវិនិយោគសាធារណៈតាមបទពិសោធន៍ល្អ ដែលសំរេចលទ្ធផល

ល្អប្រសើរ ក្នុងការអនុវត្តគំរោងស្តារបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធ ដែលបានរងការខូចខាតដោយទឹកជំនន់ នៅ ឆ្នាំ ២០០០ កន្លងមក។

៣- ប្រគល់ភារកិច្ចជូនក្រសួងផែនការ ធ្វើជាសេនាធិការផ្ទាល់អោយរាជរដ្ឋាភិបាល និងជាច្រកតែមួយគត់ ក្នុងការគ្រប់គ្រង តាមដាន និងសំរបសំរួលរាល់គំរោងវិនិយោគសាធារណៈ ដូចជា ការប្រើប្រាស់ក្របខ័ណ្ឌជំនួយ និងកម្ចីពីបរទេស ក្នុងនោះរួមមាន ធនាគារ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ជំនួយឬកម្ចីទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល និងថវិការដ្ឋ ហើយត្រូវធ្វើរបាយការណ៍រួម ស្តីពីលទ្ធផលនៃការអនុវត្តគំរោងវិនិយោគសាធារណៈ ជូនរាជរដ្ឋាភិបាលតាមកាលកំណត់ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងខេត្ត-ក្រុង ត្រូវបង្កើនកិច្ចសហការអោយបានជិតស្និទ្ធជាមួយក្រសួងផែនការ ដើម្បីធ្វើការផ្សព្វផ្សាយ និងចាត់ចែងអនុវត្តតាមស្មារតី និងខ្លឹមសារដូចបានចែងខាងលើ អោយបានល្អត្រឹមត្រូវ និងទទួលបានលទ្ធផលជាវិជ្ជមាន។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-គ្រប់សាលាខេត្ត-ក្រុង
-ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

№ ៣៤០ ៦៥៤.ឧករធរ.-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០៤.

ប្រកាស
ស្តីពីការចុះបញ្ជី និងលក្ខខ័ណ្ឌនៃការផ្តល់ ការពន្យាបន្ត និង ការផ្ទេរសិទ្ធិ នៃអាជ្ញាប័ណ្ណធនធានរ៉ែ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញ អនុក្រឹត្យលេខ ៣៥ អនក្របក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

សំរេច

ប្រការ ១.-

ប្រជាពលរដ្ឋខ្មែរ ឬរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងដាក់ពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែ រួមមានៈ

១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ

២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម

៣- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ

៤- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ និង

៥- អាជ្ញាប័ណ្ណស្វែងរុករក

ដើម្បីស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែ ឬកែច្នៃធនធានរ៉ែ ឬមានបំណងទទួលការផ្ទេរសិទ្ធិ [illegible] ទាំង ណាមួយដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវធ្វើការចុះបញ្ជីជាមុន នៅតាមទីកន្លែងដូចខាងក្រោម [illegible]

ក- សំរាប់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ - ត្រូវធ្វើការចុះបញ្ជីនៅមន្ទីរ ឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុងដែលតំបន់សំរាប់ធ្វើការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែនៅ [illegible]

តែបែបបទនៃការចុះបញ្ជីសំរាប់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ដែលត្រូវកំណត់នៅក្នុងប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីប្រតិភូកម្មអំណាចនៃការងារឧស្សាហកម្ម រ៉ែ និងថាមពល ជូនដល់បណ្តាស្រុកនៃខេត្តមួយចំនួន។

ខ- សំរាប់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត - ត្រូវធ្វើការចុះបញ្ជី នៅអគ្គនាយកដ្ឋានធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

អគ្គនាយកដ្ឋានធនធានរ៉ែ និង មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីក្នុងរយៈពេលប្រាំពីរ (០៧) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសំណុំលិខិតសុំចុះបញ្ជីគ្រប់គ្រាន់ ដូចបានកំណត់ក្នុងប្រកាសនេះ ។

ប្រការ ២.-

សំណុំលិខិតសុំចុះបញ្ជីសំរាប់អាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម :

២.១ សំរាប់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ និងអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ត្រូវរួមមាន :

(ក) ពាក្យសុំចុះបញ្ជី (មានបិទតែម ១.០០០រៀល) .... ចំនួន ១ច្បាប់

(ខ) ប្រវត្តិរូបមានបិទរូបថត៤x៦ ដោយមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន .... ចំនួន ១ច្បាប់

(គ) ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ប័ណ្ណគ្រួសារ ដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម .... ចំនួន ១ច្បាប់

២.២ សំរាប់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ត្រូវរួមមាន :

(ក) ពាក្យសុំចុះបញ្ជី (មានបិទតែម ១.០០០រៀល) .... ចំនួន ១ច្បាប់

(ខ) ប្រវត្តិរូបមានបិទរូបថត៤x៦ ដោយមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន .... ចំនួន ១ច្បាប់

(គ) ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ច្បាប់ចម្លងលិខិតឆ្លងដែនដែលមានសុពលភាពដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម .... ចំនួន ១ច្បាប់

(ឃ) លិខិតបញ្ជាក់អាស័យដ្ឋានក្រុមហ៊ុន ដោយមានការបញ្ជាក់ពីសាលាខេត្ត-ក្រុង ចំនួន ១ច្បាប់

(ង) ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីការនៅក្រសួងពាណិជ្ជកម្ម ដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម .... ចំនួន ១ច្បាប់

(ច) ច្បាប់ចម្លងលក្ខន្តិកៈសហគ្រាសចំរុះ ....ចំនួន ១ច្បាប់
(ហើយប្រសិនបើជាក្រុមហ៊ុនសហគ្រាសចំរុះ ត្រូវលំអិតពីទំនាក់ទំនងការទទួលខុសត្រូវចំណែកភាគហ៊ុន និងការចាត់តាំងជាការិប្រតិបត្តិ ....ចំនួន ១ច្បាប់)

ប្រការ ៣.-

ប្រជាពលរដ្ឋខ្មែរ ឬ រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានចុះបញ្ជីរួច អាចដាក់ពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែ នៅតាមទីកន្លែង ដូចខាងក្រោម :

ក- សំរាប់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ - ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណ នៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ដែលតំបន់សំរាប់ធ្វើការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែនោះតាំងនៅ លើកលែងតែបែបបទនៃការដាក់ពាក្យសុំ និងការផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ដែលត្រូវកំណត់នៅក្នុងប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីប្រតិភូកម្មអំណាចនៃការងារឧស្សាហកម្ម រ៉ែ និងថាមពល ជូនដល់បណ្តាស្រុកនៃខេត្តមួយចំនួន ។

ខ- សំរាប់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត — ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណ នៅអគ្គនាយកដ្ឋានធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

បន្ទាប់ពីបានទទួលសំណុំលិខិតស្នើសុំគ្រប់គ្រាន់តាមបែបបទបច្ចេកទេស អគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវដាក់សំណុំលិខិតស្នើសុំនោះជូនរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ពិនិត្យ និងសំរេច ។

ប្រការ ៤.-

សំណុំលិខិតពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម :

៤.១ សំរាប់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ និងអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ត្រូវរួមមាន :

(ក) ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ឬអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ (មានបិទតែម ១.០០០រៀល) .... ចំនួន ១ច្បាប់

(ខ) ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ឬនៅអគ្គនាយកដ្ឋានធនធានរ៉ែ .... ចំនួន ១ច្បាប់

(គ) ប្លង់ទីតាំងស្នើសុំ (មានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន) .... ចំនួន ១ច្បាប់

(ឃ) របាយការណ៍ស្តីពីសមត្ថភាពហិរញ្ញវត្ថុ (សំរាប់អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ) .. ចំនួន ១ច្បាប់

(ង) របាយការណ៍ពីកម្លាំងពលកម្ម និងឧបករណ៍សម្ភារៈ .... ចំនួន ១ច្បាប់

៤.២ សំរាប់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ត្រូវរួមមាន :

(ក) ពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែ (មានបិទតែម ១.០០០រៀល) .... ចំនួន ១ច្បាប់

(ខ) ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីនៅអគ្គនាយកដ្ឋានធនធានរ៉ែ .... ចំនួន ១ច្បាប់

(គ) ប្លង់ទីតាំងស្នើសុំ (មានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន) .... ចំនួន ១ច្បាប់

(ឃ) របាយការណ៍ស្តីពីសមត្ថភាពហិរញ្ញវត្ថុ ឬតុល្យភាពហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយ ៣ ឆ្នាំ របស់ក្រុមហ៊ុនដោយមានការបញ្ជាក់ពីស្ថាប័នហិរញ្ញវត្ថុ ឬសវនកម្មណាមួយ ដែលបានទទួលសិទ្ធិធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា .... ចំនួន ១ច្បាប់

(ង) កម្មវិធីការងារស្វែងរុករក/អាជីវកម្មធនធានរ៉ែ និងថវិកាសំរាប់ចំណាយ នៅក្នុងរយៈពេលប្រតិបត្តិការធនធានរ៉ែ .... ចំនួន ១ច្បាប់

(ច) បទពិសោធន៍កន្លងមករបស់ក្រុមហ៊ុនក្នុងវិស័យធនធានរ៉ែ ឬឧស្សាហកម្មពាក់ព័ន្ធ ចំនួន ១ច្បាប់

(ឆ) ការសិក្សាពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រង ផែនការស្តារឡើងវិញ និងថវិកាបំរុងសំរាប់ការស្តារឡើងវិញ .... ចំនួន ១ច្បាប់

(ជ) ផែនការជ្រើសរើសពលករកម្ពុជា និងកម្មវិធីបណ្តុះបណ្តាល .... ចំនួន ១ច្បាប់

ប្រការ ៥.-

សុពលភាពនៃអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានកំណត់ ដូចខាងក្រោម :

១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ មានរយៈពេលមួយ (០១) ឆ្នាំ

២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម មានរយៈពេលមួយ (០១) ឆ្នាំ

៣- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ មានរយៈពេលមួយ (០១) ឆ្នាំ

៤- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ មានរយៈពេលមួយ (០១) ឆ្នាំ

៥- អាជ្ញាប័ណ្ណស្វែងរុករក មានរយៈពេលពីរ (០២) ឆ្នាំ ។

ប្រការ ៦.-

លក្ខខ័ណ្ឌនៃការពន្យាបន្តអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម :

៦.១ សម្បទានិកដែលមានអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ អាចដាក់ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែថ្មី រហូតដល់ជម្រករ៉ែអស់លក្ខណៈសេដ្ឋកិច្ច មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមរយៈមន្ទីរ

ឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ដើម្បីពិនិត្យ និងសំរេច យ៉ាងហោចណាស់សាមសិប (៣០)ថ្ងៃ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែដែលកំពុងមាន ដោយអនុវត្តតាមកថាខ័ណ្ឌ ៤.១ នៃប្រការ ៤ ខាងលើ ។

៦.២ សម្បទានិកដែលមានអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ អាចដាក់ពាក្យសុំពន្យាបន្តអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីពិនិត្យ និងសំរេច យ៉ាងហោចណាស់សាមសិប (៣០)ថ្ងៃ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែដែលកំពុងមាន ដោយអនុវត្តតាមកថាខ័ណ្ឌ ៤.១ នៃប្រការ ៤ ខាងលើ ។

៦.៣ សម្បទានិកដែលមានអាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម ឬអាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ អាចដាក់ពាក្យសុំពន្យាបន្តរហូតដល់ជម្រករ៉ែអស់លក្ខណៈសេដ្ឋកិច្ច មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីពិនិត្យ និងសំរេច យ៉ាងហោចណាស់សាមសិប (៣០)ថ្ងៃ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម ឬអាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃដែលកំពុងមាន ដោយភ្ជាប់មកជាមួយនូវ :

(ក) លិខិតស្នើសុំការពន្យាបន្តអាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម ឬ អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ .... ចំនួន ១ច្បាប់

(ខ) របាយការណ៍ស្តីពីលទ្ធផលនៃការស្វែងរុករក និង/ឬការធ្វើអាជីវកម្មធនធានរ៉ែ ដែលបានអនុវត្តក្នុងរយៈពេលនៃអាជ្ញាប័ណ្ណមុន .... ចំនួន ១ច្បាប់

(គ) របាយការណ៍ស្តីពីការការពារបរិស្ថាននៅក្រៅនិងក្នុងការដ្ឋានរ៉ែ និងការអនុវត្តនីកម្មវិធីស្តារឡើងវិញដោយមានការបញ្ជាក់ពីមន្ទីរបរិស្ថានខេត្ត/ក្រុង .... ចំនួន ១ច្បាប់

(ឃ) តុល្យភាពគណនីសំរាប់មូលនិធិស្តារឡើងវិញ និងមូលនិធិបណ្តុះបណ្តាល .... ចំនួន ១ច្បាប់

(ង) របាយការណ៍ស្តីពីការបង់ជូនរដ្ឋនូវសួយសារ ឈ្នួលដីប្រចាំឆ្នាំ និងពន្ធអាករពាក់ព័ន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងសក្ខីប័ត្រដើម .... ចំនួន ១ច្បាប់

(ច) ផែនការស្វែងរុករក និង/ឬអាជីវកម្មធនធានរ៉ែ ផែនការស្តារការដ្ឋានរ៉ែឡើងវិញ និងកម្មវិធីបណ្តុះបណ្តាល សំរាប់រយៈពេលពន្យាបន្ត .... ចំនួន ១ច្បាប់

៦.៤ សម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករក អាចសុំពន្យាបន្តរយៈពេលស្វែងរុករកបានពីរ(០២) ដង ដោយម្តងៗមានរយៈពេលពីរ(០២)ឆ្នាំ ។ សម្បទានិកត្រូវដាក់ពាក្យសុំពន្យាបន្តអាជ្ញាប័ណ្ណស្វែងរុករក មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីពិនិត្យ និងសំរេច យ៉ាងហោចណាស់សាមសិប (៣០)ថ្ងៃ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណស្វែងរុករកដែលកំពុងមាន ដោយភ្ជាប់មកជាមួយនូវ :

(ក) លិខិតស្នើសុំការពន្យាបន្តអាជ្ញាប័ណ្ណស្វែងរុករក ....ចំនួន ១ច្បាប់

(ខ) របាយការណ៍ស្តីពីលទ្ធផលនៃការស្វែងរុករកធនធានរ៉ែ ដែលបានអនុវត្តនៅក្នុងរយៈពេលនៃអាជ្ញាប័ណ្ណមុន .... ចំនួន ១ច្បាប់

(គ) របាយការណ៍ស្តីពីការការពារបរិស្ថាននៅក្រៅនិងក្នុងការដ្ឋានរ៉ែ និងការអនុវត្តនីកម្មវិធីស្តារឡើងវិញដោយមានការបញ្ជាក់ពីមន្ទីរបរិស្ថានខេត្ត/ក្រុង .... ចំនួន ១ច្បាប់

(ឃ) របាយការណ៍ស្តីពីការបង់ជូនរដ្ឋនូវឈ្នួលដីប្រចាំឆ្នាំ និងពន្ធអាករពាក់ព័ន្ធផ្សេងៗ ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងសក្ខីប័ត្រដើម .... ចំនួន ១ច្បាប់

(ង) ផែនការស្វែងរុករក និងកម្មវិធីបណ្តុះបណ្តាលសំរាប់រយៈពេលបន្ត .... ចំនួន ១ច្បាប់

នៅចុងបញ្ចប់នៃឆ្នាំទីប្រាំមួយ (០៦) ឬ នៅឆ្នាំចុងក្រោយនៃអាជ្ញាប័ណ្ណស្វែងរុករករ៉ែ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចពន្យាបន្តនៃអាជ្ញាប័ណ្ណនេះ សំរាប់រយៈពេលបន្ថែមកំណត់មួយ ក្នុងករណី

ដែលសម្បទានិកត្រូវការពេលវេលា ដើម្បីសិក្សាពីលទ្ធភាពសេដ្ឋកិច្ចនៃជម្រករ៉ែ ឬដើម្បីដាក់ពាក្យសុំអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ នៅក្នុងតំបន់ដែលស្ថិតនៅក្នុងរង្វង់ព្រំដែននៃអាជ្ញាប័ណ្ណស្វែងរុករកនោះ ។

ប្រការ ៧.-

នៅពេលផុតសុពលភាពនៃអាជ្ញាប័ណ្ណធនធានរ៉ែ ប្រសិនបើសម្បទានិកណាមួយមិនបានដាក់ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែជាថ្មី ឬពាក្យសុំពន្យាបន្តអាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ដូចបានកំណត់ក្នុងប្រការ ៦ ខាងលើ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងដកតំបន់សម្បទាននោះមកវិញទាំងស្រុង ។ ក្នុងករណីនេះ សម្បទានិកនោះត្រូវទទួលខុសត្រូវក្នុងការជំរះបំណុលពាក់ព័ន្ធទាំងអស់ដែលរួមមានជាអាទិ៍ សួយសារ ឈ្នួលដីប្រចាំឆ្នាំ ពន្ធលើប្រាក់ចំណេញ និងពន្ធអាករពាក់ព័ន្ធផ្សេងទៀត និងមូលនិធិសំរាប់ការស្តារឡើងវិញដែលនៅសល់ មុនពេលផុតសុពលភាពនៃអាជ្ញាប័ណ្ណធនធានរ៉ែ ព្រមទាំងត្រូវទទួលខុសត្រូវក្នុងការស្តារការដ្ឋានរ៉ែទាំងឡាយ ដែលស្ថិតនៅក្រោមអាជ្ញាប័ណ្ណធនធានរ៉ែនោះ ។

ប្រការ ៨.-

ក្នុងករណីពុំទាន់មានអនុក្រឹត្យស្តីពីការផ្តល់អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ សម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករក អាចដាក់ពាក្យសុំអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ឬសុំពន្យាបន្ត ក្រោមលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងស្វែងរុករកនិង/ឬធ្វើអាជីវកម្មធនធានរ៉ែ ដែលបានចុះហត្ថលេខារវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង សម្បទានិកនោះ ។

ប្រការ ៩.-

លើកលែងតែអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ហើយដែលមានបំណងផ្ទេរសិទ្ធិទាំងស្រុងនៃអាជ្ញាប័ណ្ណធនធានរ៉ែនោះ ទៅឱ្យភាគីមួយទៀត ត្រូវដាក់ពាក្យសុំផ្ទេរសិទ្ធិ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីពិនិត្យ និងសំរេច ដោយភ្ជាប់មកជាមួយនូវ :

(ក) លិខិតស្នើសុំផ្ទេរសិទ្ធិទាំងស្រុងនៃអាជ្ញាប័ណ្ណធនធានរ៉ែ ពីភាគីផ្ទេរសិទ្ធិ ដោយមានការបញ្ជាក់មូលហេតុច្បាស់លាស់ .... ចំនួន ១ច្បាប់

(ខ) លិខិតស្នើសុំទទួលសិទ្ធិ និងការទទួលខុសត្រូវទាំងស្រុង ពីភាគីទទួលសិទ្ធិ ដោយមានការបញ្ជាក់មូលហេតុច្បាស់លាស់ .... ចំនួន ១ច្បាប់

(គ) របាយការណ៍ស្តីពីការជំរះបំណុលសួយសារ ឈ្នួលដីប្រចាំឆ្នាំ និងពន្ធអាករពាក់ព័ន្ធផ្សេងទៀត ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងសក្ខីប័ត្រដើម .... ចំនួន ១ច្បាប់

(ឃ) ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីរបស់ភាគីទទួលសិទ្ធិ នៅអគ្គនាយកដ្ឋានធនធានរ៉ែ .... ចំនួន ១ច្បាប់

(ង) របាយការណ៍ស្តីពីសមត្ថភាពហិរញ្ញវត្ថុ ឬតុល្យភាពហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយ ៣ឆ្នាំ របស់ភាគីទទួលសិទ្ធិ ដោយមានការបញ្ជាក់ពីស្ថាប័នហិរញ្ញវត្ថុ ឬ សវនកម្មណាមួយដែលបានទទួលសិទ្ធិធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា .... ចំនួន ១ច្បាប់

(ច) បទពិសោធន៍កន្លងមករបស់ភាគីទទួលសិទ្ធិ ក្នុងវិស័យធនធានរ៉ែ ឬឧស្សាហកម្មដែលពាក់ព័ន្ធ .... ចំនួន ១ ច្បាប់

(ឆ) កម្មវិធីការងារស្វែងរុករក/អាជីវកម្មធនធានរ៉ែ និងថវិកាសំរាប់ចំណាយរបស់ភាគីទទួលសិទ្ធិ នៅក្នុងរយៈពេលប្រតិបត្តិការធនធានរ៉ែ .... ចំនួន ១ច្បាប់

(ជ) ការសិក្សាពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រង ផែនការស្តារឡើងវិញ និងថវិកាបំរុងសំរាប់ការស្តារឡើងវិញ របស់ភាគីទទួលសិទ្ធិ .... ចំនួន ១ ច្បាប់

(ឈ) ផែនការជ្រើសរើសពលករកម្ពុជា និងកម្មវិធីបណ្តុះបណ្តាលរបស់ភាគីទទួលសិទ្ធិ ចំនួន ១ ច្បាប់

ប្រការ ១០.-

ក្នុងករណីអាជ្ញាប័ណ្ណធនធានរ៉ែត្រូវបានព្យួរទុក ឬដកហូត សម្បទានិកត្រូវទទួលខុសត្រូវក្នុងការជំរះបំណុលពាក់ព័ន្ធទាំងអស់ដែលរួមមានជាអាទិ៍ សួយសារ ឈ្នួលដីប្រចាំឆ្នាំ ពន្ធលើប្រាក់ចំណេញ និងពន្ធអាករពាក់ព័ន្ធផ្សេងទៀត និងមូលនិធិសំរាប់ការស្តារឡើងវិញដែលនៅសល់មុនពេលព្យួរទុក ឬដកហូតអាជ្ញាប័ណ្ណធនធានរ៉ែ ព្រមទាំងត្រូវទទួលខុសត្រូវក្នុងការស្តារការដ្ឋានរ៉ែទាំងឡាយដែលស្ថិតនៅក្រោមអាជ្ញាប័ណ្ណធនធានរ៉ែនោះ ។

ប្រការ ១១.-

អគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ១២.-

ប្រកាសនេះ មានប្រសិទ្ធភាព និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ខេត្ត-ក្រុង (ដើម្បីជូនជ្រាប)
- ដូចប្រការ ១១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ